# ដំណើរឆ្ពោះទៅថ្ងៃអនាគត

និពន្ធដោយលោកបណ្ឌិត ហ្គាហ្សារ ពាងម៉េត

ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨

*អតីតមេបញ្ជាការខ្មែរក្រហមហ៊ុនសែនដែលបានរត់ចូលយួនហាណូយនៅឆ្នាំ១៩៧៧ បានខំធ្វើធម្មានុរូបកម្មឱ្យកងទ័ពវៀតណាមកុម្មុយនិស្តជាងមួយសែននាក់ឆ្លងព្រំដែនប្រទេសខ្មែរនៅខែធ្នូ១៩៧៨ ចូលកាន់កាប់រដ្ឋធានីភ្នំពេញនៅថ្ងៃទី៧មករា១៩៧៩ រួចត្រួតត្រាទឹកដីខ្មែរដោយចេញមុខចំនួន១០ឆ្នាំរហូតដល់ឆ្នាំ១៩៨៩ ។ ឈ្ងក់ញៀននឹងអំណាចរដ្ឋ លោកបានតម្រូវឱ្យគេគោរពលោកជា «សម្តេចអគ្គមហាសេនាបតីតេជោ» ហើយលោកបានប្រកាសថា ៣៩ឆ្នាំនៃអំណាចផ្តាច់ការ (១៩៧៩-២០១៨) មិនទាន់គ្រប់គ្រាន់ទេ លោកនឹងបន្តកាន់អំណាចរដ្ឋប្រទេសកម្ពុជាយ៉ាងហោច១០ឆ្នាំទៅមុខទៀត ។ ពោលគឺអតីតខ្មែរក្រហមរូបនេះបានសំរេចរួចហើយថា លោកនិងគណបក្សប្រជាជនកាន់អំណាចនឹងយកការបោះឆ្នោតដែលនឹងធ្វើឡើងនៅខែកក្កដា ប្រាំខែខាងមុខនេះជាឧបករណ៍នយោបាយនិងជាយុត្តិកម្មថាលោកបានឈ្នះឆ្នោតបន្តអំណាចទៅមុខទៀត ។*

*សេចក្តីពិពណ៌នាយ៉ាងខ្លីខាងលើនេះគឺដើម្បីបង្ហាញនូវគន្លងផ្លូវនយោបាយនៅកម្ពុជានៅក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំអាចចាប់ផ្តើមកំណត់អនាគតរបស់ខ្មែរប្រជាធិបតេយ្យដែលនៅជ្រួលច្របល់ខំអំពាវនាវដល់សហគមន៍អន្តរជាតិសុំជួយ «ពង្រស់» ទ្វិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ដើម្បីឱ្យការបោះឆ្នោតនៅខែកក្កដាមានលក្ខណៈសេរីនិងយុត្តិធម៌ ។ ទោះបីមានរដ្ឋាភិបាលបរទេសខ្លះនិងសភាអឺរ៉ុបបានធ្វើការព្រមានដល់ «តេជោហ៊ុនសែន» ក៏គេអាចមើលឃើញដូចនៅលើគោកថា ព្រមានក៏ព្រមានទៅ តែកិច្ចការរដ្ឋរវាងរដ្ឋាភិបាលដែលបានព្រមាននិងរដ្ឋាភិបាលខ្មែរផ្តាច់ការនៅតែបន្តជាប្រក្រតី ហាក់ដូចជាពាក្យស្លោកខ្មែរថែងថា «កោកៗសឹកតែមាត់ត្រដោក ឆ្អែតតែពោះក្របី» ។*

ទោះជាយ៉ាងនេះហើយក្តី ក៏ខ្មែរប្រជាធិបតេយ្យហាក់ដូចជាស្វែងរកសាមគ្គីភាពរវាងគ្នានិង រវាងក្រុមមិនទាន់ឃើញដែរ ។ ប៉ុន្មានថ្ងៃកន្លងទៅនេះ គេឃើញមានអ៊ីម៉ែលបង្ហោះតាមអ៊ិនធឺណេតអំពាវនាវសុំខ្មែរនានាដែលប្រឆាំងដូចគ្នានឹងអំណាចផ្តាច់ការហ៊ុនសែនរួបរួមគ្នាឡើងជា «សាមគ្គីភាពពហុវចនៈ» បង្កើតជាសកម្មភាពរួម ដេញជនផ្តាច់ការឱ្យខ្ទាតចេញពីអំណាចសិន ។ ចាស់ទុំខ្មែរបានចងជាពាក្យស្លោករួចមកហើយអំពីឈើរៀច ឈើត្រង់ ឈើសាំរញ៉ាំ ដែលសុទ្ធតែមានប្រយោជន៍ ។ ម្ហូបសំរាប់គំនិតដែលខ្ញុំបានចងក្រងជូនថ្លៃងអំពីគំនិតរចនាឆ្នៃប្រឌិតជម្រុញព្រឹត្តិការណ៍ សកម្មភាព និងកាលៈទេសៈឱ្យវាហូរចូលគ្នាជាសន្ទុះចរន្តប្រដេញគ្នាទៅចូលចំណុចកំពូលមួយហើយហូរធ្លាយពន្លិចអំណាចផ្តាច់ការដែលកាន់ក្តោបដោយជនផ្តាច់ការដែលមានជើងជាដីឥដ្ឋអាចយកកូនញញួរឈើទៅដំក៏វាបែកខ្ចាយបានដែរ ។

ជាអកុសល ខ្មែរប្រជាធិបតេយ្យនៅរកសាមគ្គីភាពមិនបាន ព្រោះបុគ្គលខ្មែរម្នាក់ៗនៅរស់ក្នុងការបែកបាក់ជាមួយខ្លួនឯងនៅឡើយ ខ្វះសាមគ្គីភាពជាមួយខ្លួនឯង ព្រោះខ្វះគោលការណ៍ណែនាំ ខ្វះឧត្តមគតិខ្ពង់ខ្ពស់ជាពន្លឺបង្ហាញផ្លូវ នៅប្រូបូកប្របល់នឹងអ្វីដែលជាប្រយោជន៍ផ្ទាល់ខ្លួន តាំងពី «អាត្មាអញ» ដល់ «ក្រុមអញ» «មេអញ» ដែលបង្ហាញនូវកង្វះនៃការគិតនិងការត្រិះរិះ ពិចារណាដើម្បីកំណត់អនាគតរបស់យើង -- គ្រួសារយើង ក្រុមហ៊ុនយើង សហគមន៍យើង និងប្រទេសជាតិយើង ។ តាមការប្រៀនប្រដៅព្រះពុទ្ធ មនុស្សយើងជាផលិតចេញពីគំនិតរបស់យើង ពិភពដែលយើងរស់នៅគឺជាពិភពដែលយើងបានបង្កើតស្របទៅតាមការគិតរបស់យើង ។

សុខុមាលភាពសាធារណៈគឺជាសុខុមាលភាពសំរាប់មនុស្សទាំងអស់គ្នានៅក្នុងសង្គម ។ របបអំណាចផ្តាច់ការដែលចំរាញ់យកប្រយោជន៍ដើម្បីបំរើ «អាត្មាអញ» និង «បក្សពួកអញ» គឺមិនបានបំរើទេ តែវាបានបំផ្លាញសុខុមាលភាពសាធារណៈនោះទៅវិញ ។ បញ្ហាធំមួយនៅពេលដែលសកម្មជនខ្មែរប្រជាធិបតេយ្យងើបឈរធ្វើសកម្មភាពបំរើ សុខុមាលភាព

សាធារណៈដោយឈមមុខតទល់នឹងរបបគ្រប់គ្រងផ្តាច់ការ គេឃើញមាន ជម្ងឺខ្មែរ «ចាំបាយឆ្អិន» កើតមានឡើង ។ គេសង្កេតឃើញមានខ្មែរខ្លះសុខចិត្តនៅឈរមើល

> **លោក អេឌម៉ុនដ៍ បឿរ៍គ ( Edmund Burke )**
>
> *អ្នកគិតនយោបាយអភិរក្សជាតិអៀរឡង់ (១៧២៩-១៧៩៧)*
>
> **«រឿងតែមួយគត់ដែលចាំបាច់សម្រាប់ជ័យជំនះនៃអំពើអាក្រក់ គឺមនុស្សល្អនៅស្ងៀមមិនធ្វើអ្វីសោះ» ។**

កិច្ចប្រឹងប្រែងរបស់សកម្មជនជាជាងលាត់ដៃអាវជួយមួយដៃមួយជើង ដូចជារត់រកអុស រកចន្ទុះ រកទឹក ជួយបង្កាត់ភ្លើងដាំបាយ ដើម្បីជា ប្រយោជន៍សំរាប់មនុស្សទាំងអស់ក្នុងសង្គម លុះពេលបាយឆ្អិនទើបគេស្ទុះចូលរួមបាយដែរ ។ ជាការល្អដែរ បើនៅពេលសកម្មជននានាទាំងឡាយខំប្រឹងខ្នះខ្នែងហើយគេមិនយក ជើងទៅរាទឹក មិនរិះគន់ដៀមដាមបន្ថែម តែមនុស្សឈរមើលហើយចាំតែត្រូវយកប្រយោជន៍ជាមនុស្សមិនបានជួយបញ្ឈប់ទង្វើបង្ក្កិនបង្ក្រាបរបស់ជនផ្តាច់ការ ។ ជម្ងឺ «ចាំបាយឆ្អិន» អាចប្រៀបទៅនឹងវិញ្ញតិ «free-riders» ឬ «អ្នកជិះឥតបង់កម្រៃ» គឺទុកឱ្យអ្នកដទៃគេបំពេញកិច្ចការទៅលុះបានដល់ត្រើយក៏ទៅចុះត្រើយនឹងគេទៅ ។

គេអាចមើលឃើញអ្នក «ចាំបាយឆ្អិន» ឬ «អ្នកជិះឥតបង់កម្រៃ» នៅក្នុងសង្គមជាតិក៏ដូចជានៅលើឆាកអន្តរជាតិដែលមានរដ្ឋាភិបាលនៃប្រទេសនិមួយៗដែលដឹងដែរថា អតីតខ្មែរក្រហមហ៊ុនសែននិងបនរបស់លោកបានជាន់ឈ្លីលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សនៅកម្ពុជាព្រមទាំងកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ដែលជាច្បាប់អន្តរជាតិ ក៏ប៉ុន្តែរដ្ឋាភិបាលនិមួយៗនៅក្នុងសហគមន៍អន្តរជាតិគេឃើញមាននៅក្នុងផលប្រយោជន៍របស់គេទុកឱ្យ (និងសង្ឃឹមថា) រដ្ឋាភិបាលដទៃទៀតនឹងកម្រើកធ្វើអ្វីមួយឬធ្វើអ្វីពីរ ។ តែយើងបានដឹង

ហើយថា រដ្ឋាភិបាលនានាគេធ្វើអន្តរាគមនៅពេលណាទង្វើរបស់គេបំរើផលប្រយោជន៍ជាតិគេ ។ នៅក្នុងឆាកនយោបាយ ខណៈពេលណាផលប្រយោជន៍ជាតិរបស់គេប៉ះទង្គិចនឹងបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ផលប្រយោជន៍ជាតិរបស់គេតែងតែឈ្នះជាដរាប ។ ឯណាមួយខ្មែរប្រជាធិបតេយ្យរញ៉ីរញ៉ៃដូចក្តាមក្នុងចង្អេរ ឯណាមួយទៀតបក្សខ្មែរជំទាស់មិនទាន់បានទទួលនូវទំនុកទុកចិត្តពីរដ្ឋាភិបាលនានានៅឡើយ ។ យ៉ាងនេះយើងមិនត្រូវឆ្ងល់ទេ បើបរទេសគេនិយាយថា កិច្ចការងារធ្វើឡើងជាមួយបិសាចដែលគេបានស្គាល់វាប្រសើរជាងជាមួយបិសាចដែលគេមិនស្គាល់ ។

មេចលនាតស៊ូសិទ្ធិមនុស្សជាតិអាមេរិកាំងស្បែកខ្មៅឈ្មោះ លោក ម៉ាវ៍ទិន លូធើរ៍ ឃិង (Martin Luther King, Jr. ១៩២៩-១៩៦៨ ) បាននិយាយថា «យើងកម្ររកឃើញមានមនុស្សដែលមានចិត្តស្មោះស្ម័គ្រគិតគូរអំពីបញ្ហាដ៏ពិបាកនិងមានជម្រៅ ។ វាហាក់ដូចជានៅពាសពេញពិភពលោកមានតែមនុស្សដែលឆ្វាត់ឆ្វែងស្វែងរកចម្លើយដែលងាយស្រួល និងរកដំណោះស្រាយដែលឆ្អឹនពាក់កណ្តាល ។ គ្មានអ្វីធ្វើឱ្យមនុស្សខ្វះមានការលំបាកច្រើនជាងតម្រូវឱ្យធ្វើការគិតគូរឡើយ » ។ លោកបានបន្ថែមទៀតថា «មុខងារនៃការអប់រំគឺបង្រៀនមនុស្សឱ្យចេះគិតយ៉ាងស៊ីជម្រៅនិងយ៉ាងពិចារណា ។ គោលដៅពិតនៃការអប់រំគឺបណ្តុះឱ្យមនុស្សមានបញ្ញាវៃឆ្លាតរួមនឹងចរិតចរិយាល្អប្រសើរ» ។

ដោយហេតុថា «ការគិតយ៉ាងស៊ីជម្រៅនិងយ៉ាងពិចារណា» វាតម្រូវឱ្យប្រើខួរក្បាលធ្វើសកម្មភាពប្រើគំនិតជាច្រើនផ្នែក ដំណោះស្រាយងាយស្រួលបំផុតសំរាប់ខ្មែរ យើងគឺបន្តទម្លាប់ប្រើ «គំនិតបន្តពូជ» reproductive thinking បដិសេធជាស្វ័យប្រវត្តនូវការទទួលខុសត្រូវហើយចង្អុលដាក់និងបន្ទោសអ្នកដទៃថាជាបុព្វហេតុនៃបញ្ហាផងទាំងឡាយនោះ ។ ប៉ុន្តែព្រះពុទ្ធបានប្រដៅរួចមកហើយថា គឺបុគ្គលយើងនេះឯងដែលជាអ្នកទទួលខុសត្រូវលើអ្វីៗទាំងអស់ដែលកើតមានឡើង ហើយគ្មាននរណាមកជួយយើងក្រៅពីយើងត្រូវជួយ

ខ្លួនយើងទេ ។ អ្វីដែលយើងត្រូវការគឺបណ្ដុះបណ្ដាល «គំនិតបង្កើតផលិត» productive thinking ស្រមើលស្រមៃរចនាច្នៃប្រឌិត ។

**លោក ហ្សក ប៊ើរណាដ ហ្សយ៍ (George Bernard Shaw)**

*អ្នកនិពន្ធនិងជាអ្នករិះគន់ជាតិអៀរឡង់ (១៨៥៦-១៩៥០)*

**«លទ្ធភាពមានច្រើនណាស់នៅពេលយើងសំរេចចិត្តធ្វើសកម្មភាពជាជាងធ្វើប្រតិកម្ម» ។**

ពាក្យសំដីរបស់បិតាស្ថាបនិកសហភាពអឺរ៉ុបម្នាក់ដែលមានសញ្ជាតិបារាំងឈ្មោះហ្សង់ម៉ុណេ្ណ (Jean Monnet ១៨៨៨-១៩៧៩) ដែលខ្ញុំបានលើកមករំឭកមិនឈប់បានអះអាងថា មនុស្សលោកអាចបង្កើតអ្វីឱ្យមានបាន បើចង់ឱ្យនៅមានបានគង់វង្សយូរអង្វែងត្រូវតែមាន «ស្ថាប័ន» ដែលមានអាយុជីវិតយូរអង្វែងជាច្រើនតំណមនុស្សលោក ។ «ស្ថាប័ន» ត្រូវមានបុគ្គលមនុស្សធ្វើការរួមគ្នា នៅក្រោមច្បាប់ទម្លាប់ដែលបុគ្គលមនុស្សបានបង្កើត ដើម្បីឈោងចាប់គោលដៅរួមរបស់គេឱ្យបាន ។ ទស្សនៈរបស់លោក ហ្សង់ម៉ុណេ្ណ គ្មានអ្វីផ្ទែកពីការប្រៀនប្រដៅរបស់ព្រះពុទ្ធឡើយ ។
ឆ្នាំ២០១៨ជាឆ្នាំដែលផ្ដល់ផលវិបាកធ្ងន់ធ្ងរមួយដល់ប្រទេសខ្មែរ ជាពិសេសដល់ខ្មែរប្រជាធិបតេយ្យ ។ តែ២០១៨ក៏ជាឆ្នាំដែលផ្ដើមដំណើរឆ្ពោះទៅកាន់ថ្ងៃអវសានរបស់លោកហ៊ុនសែនដែរ ។ សកម្មជនតស៊ូមតិប្រជាធិបតេយ្យត្រូវបង្កើតជំនឿយ៉ាងមាំដូចថ្មដាថា ១. ខ្លួនអ្នកជាភ្នាក់ងារនៃការកែប្រែផ្លាស់ប្ដូរដែលចង់ឃើញ ២. របបផ្ដាច់ការអាចត្រូវគាស់រំលំបាន ។

**លោក ប្លេ តូ (ប្លាតុង)**

*បិតាស្ថាបនិកម្នាក់នៃអរិយធម៌លោកខាងលិច (៤២៨ មគស-៣៤៨ មគស)*

**«អ្នកប្រាជ្ញនិយាយស្ដីព្រោះគេមានអ្វីដែលត្រូវតែនិយាយស្ដី អ្នកល្ងង់និយាយស្ដីព្រោះគេត្រូវតែនិយាយស្ដីអំពីអ្វីមួយ» ។**

**អំពីអ្នកនិពន្ធ៖** *លោកបណ្ឌិត ហ្គាហ្វារ ពាងម៉េត អតីតយុទ្ធជនកងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ* (*ឆ្នាំ ១៩៨០-១៩៨៩*) *បានបង្រៀនវិទ្យាសាស្ត្រនយោបាយចំនួន១៣ឆ្នាំ នៅសាកលវិទ្យាល័យកោះ* Guam (*ឆ្នាំ១៩៩១-២០០៤*) *។ លោកបានចូលនិវត្តន៍ក្នុងឆ្នាំ២០០៤ ហើយបច្ចុប្បន្ននេះលោករស់នៅក្នុងសហរដ្ឋអាមេរិក។ លោកអ្នកអាចទាក់ទងនឹងលោកបានតាមរយៈសារ អេឡិចត្រូណិច* (e-mail)

peangmeth@gmail.com